## ១_ការថែទាំ :

ដំណាំប៉េងប៉ោះត្រូវការជីច្រើនប្រភេទ ដោយបែងចែកការប្រើប្រាស់ជីទៅតាមដំណាក់កាលលូតលាស់មានបួនដំណាក់កាល :

_ដំណាក់កាលទី១ :ប្រើប្រាស់ដោយទ្រាប់បាតដាក់នៅពេលភ្ជួររាស់ មុនពេលដាំឬស្ទូង ។

_ដំណាក់កាលទី២ :ពេលជ្រុំ និងពូនគល់ដំបូងគឺក្រោយពីដាំបាន ១០_១៥ ថ្ងៃ ដោយដាក់ជីអ៊ុយរ៉េ ៤៦% ចំនួន ៧០ គ.ក្រ/ហ.ត ឬ យកទៅលាយទឹកស្រោចក៏បាន ។

_ដំណាក់កាលទី៣ : ពេលប៉េងប៉ោះមានអាយុកាលបាន ២៥_៣០ថ្ងៃ ត្រូវបន្ថែមជី ១៥_១៥_១៥ ចំនួន ២០០ គ.ក្រ/ហ.ត ដោយជីកកប់ជីចំងាយពីគល់ ១០_១៥ ស.ម ធ្វើយ៉ាងណាកុំអោយដាច់ប្រព័ន្ធឫសរបស់វាដែលនាំឱ្យអន់ដើម ។

_ដំណាក់កាលទី៤ : ក្រោយពីប្រមូលផលបានមួយលើក បើដើមប៉េងប៉ោះមានការប្រែពណ៌ ត្រូវថែមជី ១៥_១៥_១៥ ចំនួន ១០០ គ.ក្រ/ហ.ត ទៀត ។

## _ការដោតចំណារ :

កសិករយើងមិនទំលាប់ប្រើដោតចំណារទេ គឺគាត់ដាំទុកឱ្យវារលើដី ដែលធ្វើអោយដើមមានភាពស្មោក សិប់ទ្រុបជាមួយស្មៅនិងងាយមានការបំផ្លាញពីសត្វល្អិតជាច្រើន ជាពិសេសដង្កូវចោះផ្លែ នឹងធ្វើឱ្យផ្លែរលួយស្អុយច្រើន ដោយសារដើមដួលផ្លែប៉ះផ្ទាល់នឹងដី ។ ការដោតចំណារមានប្រសិទ្ធិភាពខ្ពស់ ពុំសូវមានការបំផ្លាញពីពពួកសត្វល្អិត និងងាយស្រួលក្នុងការថែទាំ បាញ់ថ្នាំនិងទទួលបានពន្លឺថ្ងៃគ្រប់គ្រាន់ ។

## _ការកាត់មែក :

ប៉េងប៉ោះជាប្រភេទដំណាំដែលមានដុះខ្នែងតាំងពីគល់ជាប់ដី រហូតដល់ផ្នែកខាងលើ ។ ចាំបាច់ត្រូវកាត់ខ្នែង ២_៣ ផ្នែកខាងក្រោមចោល ។ ការទុកខ្នែងច្រើនធ្វើឱ្យដើមប៉េងប៉ោះសិប់ទ្រុប លំបាកក្នុងការថែទាំនិងមានផ្លែតូច ។

## _ការស្រោចស្រព :

ដំណាំប៉េងប៉ោះជាដំណាំត្រូវការទឹកតិច ការបញ្ចូលទឹកត្រូវធ្វើឡើងដោយបញ្ចូលតាមចង្អូរចន្លោះរងក្នុងកំរិត ២/៣ នៃរង ។ បើស្រោចដោយប៉ោតមិនត្រូវឱ្យលិចគល់ឡើយ ។

## _សត្វល្អិតនិងជម្ងឺ :

ចាប់ពីពេលដាំរហូតដល់ពេលប្រមូលផលតែងតែមានការបំផ្លាញពីសត្វល្អិតតាមដំណាក់កាលលូតលាស់របស់ដំណាំប៉េងប៉ោះ ។ នៅក្នុងដំណាក់កាលលូតលាស់មានរងការបំផ្លាញដោយពពួកមមាច ប៉ុន្តែនៅក្នុងពេលចេញផ្កា និងផ្លែមានទទួលរងការបំផ្លាញពីពពួកដង្កូវចោះផ្លែ (Fruit worm) ដង្កូវហ្វូង ( Spodoptera litura ) ដង្កូវស៊ីជាលិកាស្លឹក ( Leaf miner ) នៅរដូវក្តៅមានការកើនឡើងយ៉ាងខ្លាំង ។

## _វិធានការការពារ :

ជំងឺផ្សិតច្រើនធ្វើឱ្យរលួយគល់ និងជំងឺចំណុចពណ៌ត្នោតនៅលើស្លឹក( Leaf-Mold )ដោយអាកាសធាតុក្តៅហើយសើម ។ យើងត្រូវធ្វើអនាម័យចំការឱ្យបានស្អាត បាញ់ថ្នាំកំចាត់ ដូចជាឌីយ៉ាហ្សីណុង ( Diazinon ), ស៊្យូមីស៊ីឌីន ( Sumicidin ) ក្នុងកំរិត ២៥_៣០ សេសេ ( ១ សេសេ ស្មើនឹង ១ មីលីលីត្រ ) ក្នុងទឹក ២០ លីត្រ លាយជាមួយថ្នាំផ្សិតកាបតូម (Captom) ក្នុងកំរិត ១០_១៥ ក្រាម ។

_ដាំឱ្យសមស្របទៅតាមរដូវកាល